ស្ថានទូតអូស្ត្រាលី
ប្រចាំទីក្រុងភ្នំពេញ

# សេចក្តីប្រកាសពត៌មាន

[illegible]

## ប្រជាជនកម្ពុជាផ្តល់យោបល់ដល់អូស្ត្រាលីពីវិធីជួយជនពិការអោយកាន់តែប្រសើរឡើង

អូស្ត្រាលី នឹងជួយឧបត្ថម្ភតំណាងសំខាន់ចំនួនពីររូបនៃសហគមន៍ជនពិការដែលត្រូវបានជ្រើសតាំងជាតំណាងអោយប្រទេសកម្ពុជា នៅក្នុងសន្និបាទអន្តរជាតិ ស្តីពីជនពិការ គុណវិបត្តិ និងការអភិវឌ្ឍន៍ នៅតំបន់ អាស៊ី-បាស៊ីហ្វិក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងខេនបីរ៉ា ថ្ងៃទី២៩-៣០ កញ្ញា ២០០៨ ។

លោកស្រី **ហេង ចាន់តី** តំណាងស្ត្រីដែលមកពីអង្គការជនពិការកម្ពុជា និងលោក **គង់ វិចិត្រា** នាយកអង្គការមូលនីធិកុមារពិការ បានធ្វើការងារនេះដោយពុំមានការនឿយហត់អស់រយៈពេលជាច្រើនឆ្នាំដើម្បីលើកកំពស់សិទ្ធរបស់ បុរស-ស្ត្រី និងកុមារពិការនៅកម្ពុជា ។ លោកស្រី **ហេង** និងលោក **គង់** គឺជាជនពិការ ហើយត្រូវត្រូវបានជ្រើសរើសសំរាប់កម្មវីធីជំនួយឧបត្ថមនេះ បន្ទាប់ពីឆ្លងកាត់តំណើរការជ្រើសរើសយ៉ាងប្រកួត ប្រជែងមួយរួចមក ។

លោកជំទាវ **ម៉ាហ្គារ៉េត អាដាមសុន** ឯកអគ្គរាជទូតអូស្ត្រាលី បានមានប្រសាសន៍នៅក្នុងពិធីជំរាបលាគ្នានាថ្ងៃនេះថា "ប្រទេសអូស្ត្រាលីមានមោទនភាពយ៉ាងខ្លាំងដែលបានឧបត្ថមដល់ជនពិការកម្ពុជាដែលបានចូលរួមចំណែកក្នុងកិច្ចការដ៏មានសារសំខាន់ ដែលអង្គការជនពិការក្នុងស្រុកកំពុងតែប្រតិប័ត្តនេះ" ។

លោកស្រី **ហេង** បានមានប្រសាសន៍ថា គាត់មានសេចក្តីរំភើបយ៉ាងខ្លាំងដែលបានទៅទស្សនកិច្ចនៅប្រទេសអូស្ត្រាលី និងដើម្បីពិភាក្សាអំពីបញ្ហាដែលកំពុងប្រឈមមុខដោយជនពិការនៅប្រទេសកម្ពុជា ។ "ខ្ញុំនឹងជំរាបជូនអ្នកចូលរួមដែលមកពីបណ្តាប្រទេសផ្សេងៗគ្នា អំពីអ្វីដែលកំពុងតែកើតមានឡើងនៅប្រទេសកម្ពុជា និងនាំយកមកកម្ពុជាវិញនូវពឹតមានដែលទទួលបានពីអង្គសន្និបាត" ។

លោក **គង់** និងលោកស្រី **ហេង** នឹងផ្តល់បទឧទ្ទេសមានស្តីអំពីជនពិការ និងការអភិវឌ្ឍន៍ នៅប្រទេសកម្ពុជាជូនដល់គណៈប្រតិភូអន្តរជាតិនៅក្នុងសន្និបាត ។ តាមរយៈអង្គសន្និបាទនេះ ពួកគេទាំងពីររូបនឹងក្លាយជាផ្នែកមួយនៃក្រុមផ្តល់យោបល់ជូនទីភ្នាង់ងារអូស្ត្រាលីដើម្បីការអភិវឌ្ឍន៍អន្តរជាតិ អំពីវិធីជួយដល់ជនពិការអោយមានប្រសិទ្ធភាពប្រសើរជាងនេះ ។

បច្ចុប្បន្ន អូស្ត្រាលីកំពុងជួយដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើផែនការសកម្មភាពថ្នាក់ជាតិស្តីពីជនពីការ ។

## យុទ្ធសាស្ត្រថ្មីរបស់ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិសំរាប់ជនពិការ

នៅក្នុងខែសីហា ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) បានធ្វើការប្រជុំប្រឹក្សាយោបល់ចំនួន ១៦លើក ទូលទាំងប្រទេសកម្ពុជាដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រថ្មីរបស់ខ្លួនសំរាប់ជនពិការភាព ។ ប្រជាជនកម្ពុជា

ជាង ១២០នាក់ រួមទាំងជនពិការចំនួន ៦៧នាក់ បានផ្តល់យោបល់ដល់ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិនូវវិធីសាស្ត្រល្អៗសំរាប់ជួយគាំទ្រដល់ជនពិការនៅក្នុងបណ្តាប្រទេសកំពុងអភិវិឌ្ឍន៍ ។

លោកស្រី **បេលីនដា មើរខត** អ្នកទំនាក់ទំនងសំរាប់ការងារពិការភាពមានប្រសាសន៍ថា ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ កំពុងរៀបចំយុទ្ធសាស្ត្រស្តីពីជនពិការថ្មីមួយសំរាប់កម្មវិធីអភិវឌ្ឍន៍របស់យើង ហើយនេះជាការចាំបាច់ក្នុងការដាក់បញ្ចូលនូវទស្សនៈរបស់ជាជនពិការកម្ពុជា ។ លោកស្រីបន្តទៀតថា ពួកគេប្រាប់យើងថា ប្រជាជនដែលពិការពុំទទួលសិទ្ធិក្នុងការសិក្សាពីសេវាអប់រំ និងសុខភាព ឱកាសធ្វើការងារ និងរកប្រាក់ចំណូលឡើយ ។ ដើម្បីធ្វើអោយមានការផ្លាស់ប្តូរពិតប្រាកដសំរាប់ជីវភាពរស់នៅរបស់ជនពិការទាំងនោះ ផែនការពិការភាពដ៏មានប្រសិទ្ធីភាពមួយត្រូវតែកាត់បន្ថយនូវឥទ្ធិពលនៃភាពក្រីក្រ និងការរើសអើងដែលជនពិការ និងគ្រួសាររបស់គេកំពុងជួបប្រទះ ។ នេះជាគោលបំណងរបស់យើង ។

ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានអាត្រាអ្នកពិការខ្ពស់ជាងគេនៅក្នុងតំបន់ អាស៊ី-ប៉ាស៊ីហ្វិក ដែលបណ្តាលមកពីគ្រាប់មីនបង្កប់ក្នុងដី និងគ្រាប់មិនទាន់ផ្ទុះ ព្រមទាំងជំងឺផ្សេងៗ និងការកើនឡើងនៃគ្រោះថ្នាក់ចរាចរណ៍ ។

សំរាប់ពត៌មានបន្ថែមអំពីយុទ្ធសាស្ត្ររបស់ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ សូមមើលគេហ៍ទំព័ www.ausaid.gov.au/keyaid/disability.cfm



(ពីឆ្វេងទៅស្តាំ) លោកជំទាវ **ម៉ាហ្គារ៉េត អាដាមសុន** ឯកអគ្គរាជទូតអូស្ត្រាលី លោក **គង់ ទិចិត្រា** លោកស្រី **ហេង ចាន់តី** និងលោកស្រី **បេលីនដា មើរខត**

*ទំនាក់ទំនងសារព័តមាន: លោកស្រី **ហ្វីយ៉ូណា ខូឆ្វ** ឯកអគ្គរដ្ឋទូតរង : ០២៣ ២១៣ ៤៧០*

ស្ថានទូតអូស្ត្រាលី ប្រចាំទីក្រុងភ្នំពេញ

២៤ កញ្ញា ២០០៨